**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៦៥ "ព" ក្រ៧

ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

-សំណុំរឿងព្រហ្មទណ្ឌលេខ ២១៦៥

ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣

-សំណុំរឿងស៊ើបសួរលេខ ១៦០៥

ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣

-សំណុំរឿងជំនុំជម្រះលេខ ២៩២៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការសាធារណៈ នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង៣០នាទី នៅសាលសវនាការទី៧ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២១៦៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] ទីង ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិវៀតណាម មុខរបរជាងបាញ់ថ្នាំ ឪពុកឈ្មោះ [redacted] តែវ "ស្លាប់" ម្ដាយឈ្មោះ [redacted] ធីប៉េណាំ "ស្លាប់" នៅលើវ ជានីតិជន ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ទីកន្លែងកំណើត: ប្រទេសវៀតណាម។

អាសយដ្ឋានបច្ចុប្បន្ន: ផ្ទះលេខ២៥៩ ផ្លូវលេខ៣៦៩ ភូមិដើមម៉ាកក្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ឃាត់ខ្លួនថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣២២២ "ឈ" ដ.ឃ.ង ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣។ (ម១)

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

២. ឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិវៀតណាម មុខរបរជាងបាញ់ថ្នាំ ឪពុកឈ្មោះ [redacted] អ៊ុកសាង "ស្លាប់" ម្ដាយឈ្មោះ [redacted] ធីង្វៀង "រស់" នៅលើវ ជានីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារព្រៃស រយៈពេល០១ឆ្នាំ ពីបទ លួច(ចេញពីពន្ធនាគារកាលពីខែធ្នូ ឆ្នាំ២០២២) ។ (ក្នុងឃុំ)

ទីកន្លែងកំណើត: [redacted] រាជធានីភ្នំពេញ។

អាសយដ្ឋានបច្ចុប្បន្ន: ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ឃាត់ខ្លួនថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣២២៣ "ឈ" ដ.ឃ.ង ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣។ (ម១)

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។



Scanned with CamScanner

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សាដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្ត នៅចំណុចផ្ទះលេខ២៥៩ ផ្លូវលេខ៣៦៩ ភូមិដើមម៉ាកក្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផេង ភេទប្រុស អាយុ៤៥ឆ្នាំ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះលេខ២៥៩ ផ្លូវលេខ៣៦៩ ភូមិដើមម៉ាកក្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង០១ និង២០នាទី រំលងអធ្រាត្រ នៅចំណុចផ្ទះលេខ២៥៩ ផ្លូវ៣៦៩ ភូមិដើមម៉ាកក្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] ទឹង ,ឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ និងឈ្មោះ ចិត្រ ភេទប្រុស បានធ្វើសកម្មភាពយកដែកគ្លឹះសោទ្វារផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] ផេង លួចយកបានជណ្តើរ អ៊ីណុកចំនួន០១ ទៅលក់នៅកន្លែងអេតចាយបានប្រាក់ចំនួន ៦៨.០០០(ប្រាំមួយម៉ឺនប្រាំបីពាន់)រៀល ចែកគ្នា។ លុះដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ក៏ត្រូវបានកម្លាំងកងរាជអាវុធហត្ថ ឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ទឹង និងឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ យកមកសាកសួរ និងចាត់ការតាមនីតិវិធី ចំណែកឈ្មោះ ចិត្រ គេចខ្លួនបាត់។

-បានឃើញ របាយការណ៍សរុបលេខ ៩៤ រ.ប.ក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៦៩៦ អ.យ.ប ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣។

-បានឃើញ ដីកាដំណោះស្រាយលេខ ៣៥៣០ “ឃ” ដ.ង ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣។

**នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ [redacted] ទឹង បានឆ្លើយថា នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ២៣ និង០០នាទីអធ្រាត្រ ឈ្មោះ ចិត្រ បានបបួលខ្លួនទៅលួចទ្រព្យសម្បត្តិអ្នកដទៃ ដោយបានជិះម៉ូតូម៉ាក HONDA C125 ពណ៌ខ្មៅ គ្មានផ្លាកលេខ ពេលជិះដល់ផ្លូវព្រែកបារាំង ឃើញផ្ទះមួយកន្លែងចាក់សោពីក្រៅ ដោយឃើញសភាពស្ងាត់ឈ្មោះ ចិត្រ បានឱ្យដែកគ្លឹះសោមកខ្លួនដើម្បីគ្លឹះសោផ្ទះនោះ រួចចូលក្នុងផ្ទះនោះឃើញជណ្តើរអ៊ីណុកមួយ រួចខ្លួនបានលីជណ្តើរនោះចេញយកមកក្រៅ ហើយឈ្មោះ ចិត្រ បានឧបខ្លួនយកកាំជណ្តើរនោះទៅលក់ឱ្យអេតចាយបានប្រាក់ចំនួន ៦៨.០០០រៀល ដោយឈ្មោះ ចិត្រ បានឱ្យប្រាក់មកខ្លួនចំនួន ៣០.០០០រៀល។ ពេលលក់អេតចាយរួចហើយខ្លួនបានឃើញឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ នៅជិតនោះ ក៏បបួលគ្នាទៅផ្ទះនោះម្តងទៀត ដើម្បីរកមើលរបស់មានតម្លៃ ដោយពួកខ្លួនបានជិះម៉ូតូ០១គ្រឿង មានគ្នា០៣នាក់ ពេលទៅដល់ផ្ទះនោះ រកមើលទ្រព្យសម្បត្តិមានតម្លៃ ប៉ុន្តែពុំមានឃើញអ្វីនោះទេ ទើបពួកខ្លួនបំបែកគ្នាទៅផ្ទះរៀងៗខ្លួន។ រំលងបាន០២ថ្ងៃ ពេលខ្លួនកំពុងតែអង្គុយផឹកស៊ីនៅមុខផ្ទះគេ ស្រាប់តែសមត្ថកិច្ចមកធ្វើការឃាត់ខ្លួន និងយកទៅធ្វើការសាកសួរតែម្តង។ ខ្លួនទើបតែធ្វើសកម្មភាពលួច ចំនួន០១ដងនេះទេ។

ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ បានឆ្លើយថា នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០១ និង ២០នាទី រំលងអធ្រាត្រ ខ្លួនកំពុងអង្គុយលេងនៅមុខហាងម៉ាត ស្រាប់តែឃើញឈ្មោះ [redacted] ទឹង និងឈ្មោះ ចិត្រ ជិះម៉ូតូម៉ាក HONDA C125 ដោយឈ្មោះ [redacted] ទឹង បានលីជណ្តើរអ៊ីណុក យកទៅលក់ឱ្យកន្លែងទិញអេតចាយ នៅជិតម៉ាតដែលខ្លួនអង្គុយ បន្ទាប់ពីលក់រួចហើយឈ្មោះ [redacted] ទឹង បានបបួលខ្លួនទៅលួចម្តងទៀតដោយបានជិះម៉ូតូ០១គ្រឿងមានគ្នាបីនាក់ លុះ



Scanned with CamScanner

ពេលទៅដល់ឈ្មោះ [redacted] ទឹង និងឈ្មោះ ចិត្រ បានចូលទៅក្នុងផ្ទះនោះ មិនឃើញមានអីវ៉ាន់នោះឡើយ ទើបបំបែកគ្នាទៅផ្ទះរៀងៗខ្លួនទៅ។ លុះរំលងបាន២ថ្ងៃ ខ្លួនកំពុងសម្រាកនៅលើផ្ទះស្រាប់តែសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងយកទៅធ្វើការសាកសួរនៅប៉ុស្តិ៍នគរបាលតែម្តង។ ខ្លួនធ្លាប់ធ្វើសកម្មភាពលួច បានចំនួន០២ដងមកហើយ។

ក្រឡាបញ្ជីអានកំណត់ហេតុទទួលបណ្តឹងឈ្មោះ [redacted] ផេង បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ ខ្លួនបានឱ្យកម្មករជួយសំអាតផ្ទះរបស់ខ្លួនមានអាសយដ្ឋានផ្ទះលេខ ២ ផ្លូវព្រែកបារាំង សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ។ បន្ទាប់ពីសំអាតរួចរាល់ខ្លួនបានចាក់សោបិតស្រួលបួល ហើយផ្ទះនេះមានកាំមេរ៉ាសុវត្ថិភាពដាក់នៅមុខផ្ទះស្រាប់ រួចខ្លួនបានទៅលេងខេត្តកំពត។ បន្ទាប់ពីខ្លួនមកពីខេត្តក៏មិនបានចាប់អារម្មណ៍ផ្ទះខាងលើដែរ ព្រោះឃើញបិតទ្វារ ស្រាប់ប្អូនខ្លួនសួរមានចាក់សោទ្វារផ្ទះអត់ លឺបែបនេះខ្លួនបានភ្ញាក់ខ្លួនហើយ ឆែកមើលកាំមេរ៉ាសុវត្ថិភាព ទើបដឹងថាមានចោរមួយក្រុមមានគ្នា០៣នាក់ បានធ្វើសកម្មភាពឆ្កឹះសោគាស់ទ្វារផ្ទះរបស់ខ្លួន ចូលលួចទ្រព្យសម្បត្តិមួយចំនួនមានដូចជាជណ្តើរ ដោយជិះម៉ូតូម៉ាក ឌ្រីមប៊ិច អត់ផ្លាកលេខ។ បើមើលតាមកាំមេរ៉ាពួកវាបានចូលមកផ្ទះខ្លួនចំនួន០៣លើក។ បន្ទាប់ពីលួចបានពួកវាបានគេចខ្លួនអស់។ ក្រោយមកខ្លួនបានដាក់ពាក្យបណ្តឹងនៅកន្លែងសមត្ថកិច្ចកងរាជអាវុធហត្ថខណ្ឌច្បារអំពៅតែម្តង។ ខ្លួនសំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា តាមចម្លើយរបស់ជនជាប់ចោទទាំងពីរខាងលើ និងភស្តុតាងដែលសមត្ថកិច្ចបានដកហូត ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ហេតុនេះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៦៩៦ អ.យ.ប ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទឹង បានធ្វើសេចក្តីសន្និដ្ឋានការពារថា ដោយសារនៅចំពោះមុខអង្គសវនាការកូនក្តីរបស់ខ្លួនបានឆ្លើយសារភាពនូវអំពើដែលបានប្រព្រឹត្ត និងទទួលស្គាល់កំហុស ហេតុនេះខ្លួនសុំឱ្យតុលាការមេត្តាសម្រេចដោយបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន។

លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ាំងអុក បានធ្វើសេចក្តីសន្និដ្ឋានការពារថា នៅក្នុងអង្គហេតុនេះឃើញថា ការចូលលួចលើកទី១ ដែលប្រព្រឹត្តឡើងដោយឈ្មោះ [redacted] ទឹង និងឈ្មោះ ចិត្រ ជាអ្នកចូលទៅលួចយកជណ្តើរដែកអេណុក ហើយយកទៅលក់ឱ្យអេតចាយបានប្រាក់ចែកគ្នា។ ចំពោះការចូលទៅលួចជាលើកទី២ ដែលមានឈ្មោះ ចិត្រ និងជនជាប់ចោទឈ្មោះ [redacted] ទឹង ព្រមទាំងកូនក្តីរបស់ខ្លួនឈ្មោះ [redacted] យ៉ាំងអុក ផងដែរនោះ គឺពួកគេមិនបានធ្វើសកម្មភាពលួចយកទ្រព្យសម្បត្តិអ្វីនោះទេ ហើយចំពោះប្រាក់ដែលជាផលនៃការលួចលើកទីមួយនោះ កូនក្តីរបស់ខ្លួនក៏មិនបានទទួលចំណែកនោះដែរ ហេតុដូច្នេះ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] ទឹង បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា[1]

ក.តាមដីកាដំណោះស្រាយលេខ ៣៥៣០ "ឃ" ដ.ដ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនទៅជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ២១៦៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted]ទឹង ភេទប្រុស អាយុ៣៥ឆ្នាំ និងឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ ភេទប្រុស អាយុ២៥ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សាដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅចំណុចផ្ទះលេខ២៥៩ ផ្លូវលេខ៣៦៩ ភូមិដើមម៉ាកក្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។[2]

ខ.អង្គហេតុកើតឡើងនៅចំណុចផ្ទះលេខ២៥៩ ផ្លូវលេខ៣៦៩ ភូមិដើមម៉ាកក្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ហេតុនេះជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីភ្នំពេញ។[3]

គ.អង្គហេតុកើតឡើងកាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ បើគិតរហូតមកដល់ពេលនេះ មិនទាន់ផុតអាជ្ញាយុកាលនៃបទល្មើសទេ។[4]

ឃ.បើទោះបីជាដើមបណ្តឹងឈ្មោះ [redacted] ផេង មិនមានវត្តមាន នៅចំពោះមុខអង្គសវនាការក៏ដោយ ប៉ុន្តែតំណាងអយ្យការបានធ្វើការកោះហៅគ្រប់ភាគីពាក់ព័ន្ធឱ្យចូលរួមសវនាការ ជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង៣០នាទី ត្រឹមត្រូវរួចរាល់ហើយ ហេតុនេះតុលាការអាចបន្តសវនាការ ដោយកំបាំងមុខដើមបណ្តឹងបាន។

ង.តាមរបាយការណ៍សរុបលេខ ៩៤ រ.ប.ក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានធ្វើការសន្និដ្ឋានថា ឈ្មោះ សឹង ទឹង ភេទប្រុស អាយុ៣៥ឆ្នាំ និងឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ ភេទប្រុស អាយុ២៥ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (គាស់ផ្ទះលួចទ្រព្យសម្បត្តិ) ផ្ទះលេខ២៥៩ ផ្លូវលេខ៣៦៩ ភូមិដើមម៉ាកក្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣។[5]

ច.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ សឹង ទឹង បានឆ្លើយថា នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ២៣ និង00នាទីអធ្រាត្រ ឈ្មោះ ចិត្រ បានបបួលខ្លួនទៅលួចទ្រព្យសម្បត្តិអ្នកដទៃ ដោយបានជិះម៉ូតូម៉ាក HONDA C125 ពណ៌ខ្មៅ គ្មានផ្លាកលេខ ពេលជិះដល់ផ្លូវព្រែកបាវាំង ឃើញផ្ទះមួយកន្លែងចាក់សោពីក្រៅ ដោយឃើញសភាពស្ងាត់ឈ្មោះ ចិត្រ បានឱ្យដែកគ្លឹះសោ មកខ្លួនដើម្បីគ្លឹះសោផ្ទះនោះ រួចចូលក្នុងផ្ទះនោះឃើញជណ្តើរអ៊ីណុកមួយ រួចខ្លួនបានលីជណ្តើរនោះចេញយកមកក្រៅ ហើយឈ្មោះ ចិត្រ បានឱបខ្លួនយកកាំជណ្តើរនោះទៅលក់ឱ្យអេតចាយបានប្រាក់ចំនួន ៦៨.០០០រៀល ដោយឈ្មោះ ចិត្រ បានឱ្យប្រាក់មកខ្លួនចំនួន ៣០.០០០រៀល។ ពេលលក់អេតចាយរួចហើយខ្លួនបានឃើញឈ្មោះ [redacted] យ៉ាំងអុក

---

(1).មាត្រា៣៥១ មាត្រា៣៥២ និងមាត្រា៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(2).មាត្រា២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(3).មាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(4).មាត្រា១០ និង១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(5)(ឯកសារលេខ:១) របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ។



Scanned with CamScanner

ហៅ ពៅ នៅជិតនោះក៏បបួលគ្នាទៅផ្ទះនោះម្តងទៀត ដើម្បីរកមើលរបស់មានតម្លៃ ដោយពួកខ្លួនបានជិះម៉ូតូ០១គ្រឿង មានគ្នា០៣នាក់ ពេលទៅដល់ផ្ទះនោះ រកមើលទ្រព្យសម្បត្តិមានតម្លៃ ប៉ុន្តែពុំមានឃើញអ្វីនោះទេ ទើបពួកខ្លួនបំបែកគ្នាទៅផ្ទះរៀងៗខ្លួន។ រំលងបាន០២ថ្ងៃ ពេលខ្លួនកំពុងតែអង្គុយផឹកស៊ីនៅមុខផ្ទះគេ ស្រាប់តែសមត្ថកិច្ចមកធ្វើការឃាត់ខ្លួន និងយកទៅធ្វើការសាកសួរតែម្តង។ ខ្លួនទើបតែធ្វើសកម្មភាពលួច ចំនួន០១ដងនេះទេ។

ឆ.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ុំងអុក ហៅ ពៅ បានឆ្លើយថា នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០១ និង២០នាទី រំលងអធ្រាត្រ ខ្លួនកំពុងអង្គុយលេងនៅមុខហាងម៉ាត ស្រាប់តែឃើញឈ្មោះ [redacted] ទឹង និងឈ្មោះ ចិត្រ ជិះម៉ូតូម៉ាក HONDA C125 ដោយឈ្មោះ [redacted] ទឹង បានលីជណ្តើរអ៊ីណុក យកទៅលក់ឱ្យកន្លែងទិញអេតចាយ នៅជិតម៉ាតដែលខ្លួនអង្គុយ បន្ទាប់ពីលក់រួចហើយឈ្មោះ [redacted] ទឹង បានបបួលខ្លួនទៅលួចម្តទៀតដោយបានជិះម៉ូតូ០១គ្រឿងមានគ្នាបីនាក់ លុះពេលទៅដល់ឈ្មោះ [redacted] ទឹង និងឈ្មោះ ចិត្រ បានចូលទៅក្នុងផ្ទះនោះ មិនឃើញមានអីវ៉ាន់នោះឡើយ ទើបបំបែកគ្នាទៅផ្ទះរៀងៗខ្លួនទៅ។ លុះរំលងបាន២ថ្ងៃ ខ្លួនកំពុងសម្រាកនៅលើផ្ទះស្រាប់តែសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងយកទៅធ្វើការសាកសួរនៅប៉ុស្តិ៍នគរបាលតែម្តង។ ខ្លួនធ្លាប់ធ្វើសកម្មភាពលួច បានចំនួន០២ដងមកហើយ។

ជ.តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផេង បានឆ្លើយថា នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ ខ្លួនបានឱ្យកម្មករជួយសំអាតផ្ទះរបស់ខ្លួនមានអាសយដ្ឋានផ្ទះលេខ ២ ផ្លូវព្រែកបារាំង សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ។ បន្ទាប់ពីសំអាតរួចរាល់ខ្លួនបានចាក់សោបិតស្រួលបួល ហើយផ្ទះនេះមានកាំមេរ៉ាសុវត្ថិភាពដាក់នៅមុខផ្ទះស្រាប់ រួចខ្លួនបានទៅលេងខេត្តកំពត។ បន្ទាប់ពីខ្លួនមកពីខេត្តក៏មិនបានចាប់អារម្មណ៍ផ្ទះខាងលើដែរ ព្រោះឃើញបិតទ្វារ ស្រាប់ប្អូនខ្លួនសួរមានចាក់សោទ្វារផ្ទះអត់ លឺបែបនេះខ្លួនបានភ្ញាក់ខ្លួនហើយ ឆែកមើលកាំមេរ៉ាសុវត្ថិភាព ទើបដឹងថាមានចោរមួយក្រុមមានគ្នា០៣នាក់ បានធ្វើសកម្មភាពឆ្កឹះសោគាស់ទ្វារផ្ទះរបស់ខ្លួន ចូលលួចទ្រព្យសម្បត្តិមួយចំនួនមានដូចជាជណ្តើរ ដោយជិះម៉ូតូម៉ាកទ្រីមប៊ិច អត់ផ្លាកលេខ។ បើមើលតាមកាំមេរ៉ាពួកវាបានចូលមកផ្ទះខ្លួនចំនួន០៣លើក។ បន្ទាប់ពីលួចបានពួកវាបានគេចខ្លួនអស់។ ក្រោយមកខ្លួនបានដាក់ពាក្យបណ្តឹងនៅកន្លែងសមត្ថកិច្ចកងរាជអាវុធហត្ថខណ្ឌច្បារអំពៅតែម្តង។

ឈ.សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ទឹង និងឈ្មោះ [redacted] យ៉ុំងអុក ហៅ ពៅ ដែលបានធ្វើសកម្មភាពយកដែកឆ្កឹះសោទ្វារផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] ផេង លួចយកបានជណ្តើរ អ៊ីណុកចំនួន០១ ទៅលក់នៅកន្លែងអេតចាយ គឺជាចេតនាទុច្ចរិត ក្នុងបំណងដកហូតយកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន។

ញ.តាមចម្លើយជនជាប់ចោទទាំង០២នាក់ខាងលើ តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងរបាយការណ៍សំយោគរបស់សមត្ថកិច្ច និងភស្តុតាងផ្សេងៗទៀត មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] ទឹង និងឈ្មោះ [redacted] យ៉ុំងអុក ហៅ ពៅ ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

ដ.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ទឹង និងឈ្មោះ [redacted] យ៉ុំងអុក ហៅ ពៅ ដែលបានធ្វើសកម្មភាពយកដែកឆ្កឹះសោទ្វារផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] ផេង លួចយកបានជណ្តើរ អ៊ីណុកចំនួន០១ ទៅលក់នៅកន្លែងអេតចាយបានប្រាក់យកមកចែកគ្នា បើផ្អែកតាមធាតុនីត្យានុកូលស្រមបទៅនឹងបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សាដោយការកាប់គាស់ទម្លុះទម្លាយ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។



Scanned with CamScanner

-មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ ក្នុងករណី អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា។

ឋ.ជនជាប់ចោទឈ្មោះ [redacted] ទឹង ភេទប្រុស អាយុ៣៥ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ ភេទប្រុស អាយុ២៥ឆ្នាំ ជានីតិជន មានស្មារតីល្អ មានការយល់ដឹងខុសត្រូវច្បាស់លាស់ ហើយក៏ពុំមានសញ្ញាណណាមួយបញ្ជាក់ថាជននេះមានវិបល្លាសស្មារតីអ្វីដែរ។

ឌ.អំពើដែលជនជាប់ចោទឈ្មោះ [redacted] ទឹង និងឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ជាពិសេសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជន ជាអំពើដែលច្បាប់ហាមឃាត់ និងតម្រូវឱ្យផ្តន្ទាទោស។

ឍ.តាមកំណត់ហេតុទទួលបណ្តឹង ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ផេង មិនបានទាមទារសំណងពីជនជាប់ចោទនោះទេ ហើយដើមបណ្តឹងមិនបានបង្ហាញវត្តមាននៅចំពោះមុខអង្គសវនាការ ហេតុនេះតុលាមិនគប្បីលើកយកករណីសំណងរដ្ឋប្បវេណី មកធ្វើការពិចារណានោះទេ។

ណ.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន នៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៦៩៦ អ.យ.ប ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ការស្នើសុំតុលាការនឹងលើកយកមកពិចារណា។

ត.លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទឹង បានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យតុលាការមេត្តាសម្រេចដោយបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។

ថ.លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ាំងអុក បានធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់ ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។

ទ.ជនជាប់ចោទឈ្មោះ [redacted] ទឹង និងជនជាប់ចោទឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ បានសំណូមពរសូមឱ្យលោកចៅក្រមមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ទឹង ភេទប្រុស អាយុ៣៥ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ ភេទប្រុស អាយុ២៥ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សាដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្ត នៅចំណុចផ្ទះលេខ២៥៩ ផ្លូវលេខ៣៦៩ ភូមិដើមម៉ាកក្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សម្រេច

ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ទឹង ភេទប្រុស អាយុ៣៥ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ ភេទប្រុស អាយុ២៥ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សាដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅចំណុចផ្ទះលេខ២៥៩ ផ្លូវលេខ៣៦៩ ភូមិដើមម៉ាកក្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។[6]

---

(6).មាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង០៨ និង៣០ព្រឹក ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ទីង និងឈ្មោះ [redacted] យ៉ាំងអុក ហៅ ពៅ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង៩ និង០០នាទី។[7]

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់។[8]

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| លោក [redacted] | | | |

**បានចតបម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

(7).មាត្រា៣១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(8).មាត្រា៣៨៨, មាត្រា៣៨១ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner